ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ៨២/១១-យ៉ាកជីន**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **ឈីវ ភិរម្យ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **អាំង អេងថុង**

## ភាគីនៃវិវាទ

១- **ភាគីនិយោជក**

ឈ្មោះ : **ក្រុមហ៊ុន យ៉ាកជីន (ខេមបូឌា) អ៊ីន**

អាសយដ្ឋាន : ភូមិតាកើ្ត-ផ្សារកំបូល-ព្រៃកុដ សង្កាត់កំបូល ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៨៧២ ១៦១ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- លោក អ៊ុក ចាន់ធូ ទីប្រឹក្សាក្រុមហ៊ុន

២- លោក ឡុង ហ៊ាង តំណាងសមាគមកាត់ដេរកម្ពុជា (GMAC)

២- **ភាគីកម្មករនិយោជិត**

ឈ្មោះ : - **សហព័ន្ធសហជីពអំណាចកម្មករខ្មែរ**

- **សហជីពអំណាចកម្មករខ្មែររោងចក្រ យ៉ាកជីន**

អាសយដ្ឋាន : ផ្លូវជាតិលេខ ៤ ផ្ទះលេខ ២ G ភូមិបូរីកម្មករ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល

លេខ : ០១២ ៥២៩ ៤០៤ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត៖

១- លោក ជ័យ សុវណ្ណ ប្រធានសហព័ន្ធសហជីពអំណាចកម្មករខ្មែរ

២- លោក ឡោ សុភ័ក្ត្រ អគ្គលេខាធិការសហព័ន្ធសហជីពអំណាចកម្មករខ្មែរ

៣- លោក មុំ ប៊ុនណា ប្រធានសហជីពអំណាចកម្មករខ្មែរប្រចាំរោងចក្រ

៤- លោក ព្រុំ សារិទ្ធិ អនុប្រធានសហជីពអំណាចកម្មករខ្មែរប្រចាំរោងចក្រ

៥- លោក តិ ឆេងលី លេខាធិការសហជីពអំណាចកម្មករខ្មែរ

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យកម្មករចេញទៅក្រៅរោងចក្រនៅពេលឈប់សម្រាកបាយថ្ងៃត្រង់ ដោយមិនចាំបាច់មានលិខិតស្នាមឡើយ ព្រោះជាសិទ្ធិរបស់កម្មករត្រូវបានឈប់សម្រាក។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា នៅពេលឈប់សម្រាកបាយថ្ងៃត្រង់ គឺក្រុមហ៊ុនអនុវត្តតាមគោលការណ៍ចាស់ដដែល ដោយតម្រូវឱ្យកម្មករសុំលិខិតអនុញ្ញាតចេញចូលតាមរយៈរដ្ឋបាល ឬសន្តិសុខ ព្រោះពេលឈប់សម្រាកបាយថ្ងៃត្រង់ ក្រុមហ៊ុនបានរៀបចំអាហារថ្ងៃត្រង់សម្រាប់កម្មករក្នុងរោងចក្រ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៧៣៣ ក.ប/អក/វ.ក ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១១។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ (វេលាម៉ោង ១៤:០០ នាទី រសៀល)។

**បញ្ហានៃនីតិវិធី:**

នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារបានទទួលបណ្តឹងរបស់សហជីពអំណាចកម្មករខ្មែរ លេខ ០០៦៣/១១ សសអកខ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១១ ស្តីពីការទាមទារសុំឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារមួយចំនួនឱ្យបានកាន់តែល្អប្រសើរឡើង។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាចុងក្រោយ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន០១ ចំណុច លើការទាមទារចំនួន ០៥ ចំណុច។ ចំណុចមិនសះជាចំនួន ០១ ចំណុចនេះ បានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១១ តាមរយៈរបាយការណ៍មិនសះជាលេខ ៧៣៣ កប/អក/វក ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតប្រចាំរោងចក្រមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០១ ចំណុចនេះ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ វេលាម៉ោង ០៨:៣០ នាទី ព្រឹក ប៉ុន្តែ ពុំមានចំណុចវិវាទណាមួយទទួលបានការសះជានឹងគ្នាទេ។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងសម្រេចដូចខាងក្រោម :

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន យ៉ាកជីន (ខេមបូឌា) អ៊ីន គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការផ្ទេរសិទ្ធិជូនលោកស្រី គង់ សុគន្ធា និងលោក អ៊ុក ចាន់ធូ លេខ ១៥/១១ យ.ជ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១១។

២- លិខិតលេខ ២៤៨១ ពណ.នតក ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០៥ របស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សូមបញ្ជាក់ថា ក្រុមហ៊ុន យ៉ាកជីន (ខេមបូឌា) អ៊ីន ជាក្រុមហ៊ុនវិនិយោគទុនឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់។

៣- លក្ខន្តិកៈរបស់ក្រុមហ៊ុន យ៉ាកជីន (ខេមបូឌា) អ៊ីន ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥។

THE ARBITRATION COUNCIL

៤- លិខិតសំណើដោះស្រាយរបស់ថ្នាក់ដឹកនាំសហជីពអំណាចកម្មករខ្មែររោងចក្រ យ៉ាកជីន គោរពជូនប្រធានសហព័ន្ធសហជីពអំណាចកម្មករខ្មែរ ស្តីពីសំណើជួយដោះស្រាយនៅសំណូមពររបស់កម្មករ-កម្មការិនី ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១១។

៥- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន យ៉ាកជីន ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០១១។

៦- វិញ្ញាបនប័ត្របញ្ជាក់ភាពជាតំណាងបំផុតរបស់សហជីពកម្ពុជារោងចក្រ យ៉ាកជីន លេខ ០៣៦/១០ ក.ប/វ.ប ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០។

៧- អនុសញ្ញារួមរវាងក្រុមហ៊ុន យ៉ាកជីន (ខេមបូឌា) អ៊ីន ជាមួយសហជីពកម្ពុជារោងចក្រ យ៉ាកជីន (ខេមបូឌា) អ៊ីន ចុះបញ្ជិកាលេខ ២៨៥ កប/អក/វក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១១។

៨- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន យ៉ាកជីន (ខេមបូឌា) អ៊ីន ចុះបញ្ជិកាលេខ ០១៣/០៦ ក.ប.វ/កណ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៦។

៩- លិខិតអនុញ្ញាតចេញ-ចូលរយៈពេលខ្លី របស់ឈ្មោះ ហាប់ ឌីណា ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១។

១០- លិខិតអនុញ្ញាតចេញ-ចូលរយៈពេលខ្លី របស់ឈ្មោះ Saret Sreypouv ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ ២០១១។

១១- គំរូលិខិតអនុញ្ញាតចេញ-ចូលរយៈពេលខ្លី។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត : គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន យ៉ាកជីន លេខ ៧៣៣ ក.ប/អក/វ.ក ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន យ៉ាកជីន ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០១១។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញនាយកក្រុមហ៊ុន យ៉ាកជីន ចូលរួមសវនាការលេខ ៤៦៦ កប/អក/វក/លកអ. ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១១។

២- លិខិតអញ្ជើញសហជីពអំណាចកម្មករខ្មែរនៃក្រុមហ៊ុន យ៉ាកជីន ចូលរួម សវនាការលេខ ៤៦៧ កប/អក/វក/លកអ. ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១១។

៣- លិខិតអញ្ជើញនាយកក្រុមហ៊ុន យ៉ាកជីន ចូលរួមសវនាការលើកទី២ លេខ ៤៧១ កប/អក/វក/លកអ. ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១។

៤- លិខិតអញ្ជើញសហជីពអំណាចកម្មករខ្មែរនៃក្រុមហ៊ុន យ៉ាកជីន ចូលរួម សវនាការលើកទី២ លេខ ៤៧២ កប/អក/វក/លកអ. ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន យ៉ាកជីន គឺជាក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់។ ក្រុមហ៊ុននេះមានជួលកម្មករនិយោជិតសរុប ចំនួន ប្រហែល ៣៦០០ នាក់។
- ក្រុមហ៊ុន យ៉ាកជីន មានអនុសញ្ញារួមមួយជាមួយសហជីពកម្មករនៃរោងចក្រ យ៉ាកជីន (ខេមបូឌា) អ៊ីន. ដែលបានចុះបញ្ជីការលេខ ២៨៥ កប/អក/វក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១១។
- សហជីពអំណាចកម្មករខ្មែរ គឺជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។ សហជីពនេះ មានសមាជិកចំនួន ៤០ នាក់។

**ចំណុចវិវាទ៖ កម្មករនិយោជិតទាមទារឱ្យនិយោជកអនុញ្ញាតឱ្យកម្មករនិយោជិតចេញទៅក្រៅរោងចក្រ នៅពេលឈប់សម្រាកបាយថ្ងៃត្រង់ ដោយមិនចាំបាច់មានលិខិតស្នាមឡើយ**

- តាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ត្រង់ប្រការ ៣ ផ្នែកទី៥ បានចែងថា "*កម្មករនិយោជិតធ្វើការ ៨ ម៉ោង ក្នុងមួយថ្ងៃ ឬ ៤៨ ម៉ោង ក្នុងមួយសប្តាហ៍* "។
- អនុសញ្ញារួម ប្រការ ៦ របស់ក្រុមហ៊ុនបានចែងថា "*...ពេលវេលាធ្វើការប្រចាំថ្ងៃចែកចេញជា ២ ពេល គឺ៖ ពេលព្រឹកពីម៉ោង ៧:០០ នាទី ដល់ម៉ោង ១១:០០ នាទី។ (ពីម៉ោង ១១:០០ នាទី ដល់ម៉ោង ១២:០០នាទី សម្រាកមួយម៉ោង សម្រាប់បាយថ្ងៃត្រង់)។* ***ក្រុមហ៊ុនផ្តល់អាហារថ្ងៃត្រង់មួយពេលតម្លៃស្មើ ១២៥០ រៀល ដោយឥតគិតថ្លៃ។*** *ពេលរសៀលពីម៉ោង ១២:០០ នាទី ដល់ម៉ោង ១៦:០០ នាទី ...* "។
- អនុសញ្ញារួម ប្រការ ២០ របស់ក្រុមហ៊ុនបានចែងថា "*... កម្មករនិយោជិតទាំងអស់ត្រូវបានអនុញ្ញាតឱ្យចាក ចេញពីបរិវេណរោងចក្រក្នុងម៉ោងសម្រាកត្រូវជូនដំណឹងដល់អ្នកត្រួតត្រា ដើម្បីរាប់ចំនួន និងដើម្បី សុវត្ថិភាពផងដែរ* "។
- ក្រុមហ៊ុនបានផ្តល់បាយថ្ងៃត្រង់មួយពេលជូនកម្មករនិយោជិត ប៉ុន្តែតម្រូវឱ្យពួកគាត់ពិសារនៅក្នុងបរិវេណ រោងចក្រ។ ក្នុងករណីដែលកម្មករនិយោជិតពុំចង់ពិសារបាយនៅក្នុងក្រុមហ៊ុនទេ ពួកគាត់អាចចេញទៅក្រៅ បាន ប៉ុន្តែពួកគាត់ចាំបាច់ជូនដំណឹងទៅប្រធានជួរ ក្រុម ៦ ។

- នីតិវិធីជូនដំណឹងនេះ តម្រូវឱ្យកម្មករនិយោជិតបំពេញលិខិតដែលមានទំរង់ដូចជា ឈ្មោះ អត្តលេខ ផ្នែក មុខងារ មូលហេតុ ម៉ោងចេញ និងត្រូវដាក់តំកល់កាតរបស់កម្មករនិយោជិត។ ទន្ទឹមនឹងនេះ កម្មករនិយោជិតត្រូវយកលិខិតដែលបានបំពេញរួចនេះ ទៅជូនប្រធានផ្នែកឱ្យចុះហត្ថលេខា បន្ទាប់មកគាត់ត្រូវយកលិខិតនេះជូនទៅរដ្ឋបាល ដែលមានទីតាំងនៅក្បែរច្រកចេញឱ្យបោះត្រាបន្ថែមទៀត។
- រាល់ការសុំចេញទៅក្រៅនៅម៉ោងសម្រាកអាហារថ្ងៃត្រង់ និយោជកយល់ព្រមផ្តល់ជូនទាំងអស់ ប៉ុន្តែគ្រាន់តែតម្រូវឱ្យធ្វើលិខិតជូនដំណឹង។ មូលហេតុ គឺនិយោជកងាយស្រួលគ្រប់គ្រងចំនួនកម្មករនិយោជិត ហើយងាយស្រួលផ្ទៀងផ្ទាត់ចំនួនកម្មករនិយោជិតទៅនឹងថ្លៃបាយ។
- ភាគីកម្មករនិយោជិតបានលើកឡើងថា ពួកគាត់ស្នើសុំនិយោជកចេញទៅក្រៅនេះ ដោយពុំចាំបាច់មានការចុះហត្ថលេខាពីប្រធានក្រុមទេ ពោលគឺកម្មករនិយោជិតអាចជូនដំណឹងទៅត្រឹមរដ្ឋបាល ដែលមានទីតាំងនៅផ្លូវចេញបានហើយ ហើយចំពោះការបំពេញលើលិខិតសុំចេញនោះ គឺបំពេញតែអត្តលេខរបស់កម្មករនិយោជិត និងលេខជួរក្រុមបានហើយ ពោលគឺពុំចាំបាច់ដាក់កាតតំកល់ទេ។
- កម្មករនិយោជិតបានបញ្ជាក់ថា មូលហេតុនៃការទាមទារនេះ គឺ យោងទៅតាមមាត្រា ១៣៨ នៃច្បាប់ស្តីពីការងារ អនុសញ្ញារួមរបស់ក្រុមហ៊ុនត្រង់ប្រការ ៦ និងប្រការ ២០។ ទន្ទឹមនឹងនេះដែរ ការចេញទៅក្រៅនៅម៉ោងសម្រាកពីការងារ គឺជាសិទ្ធិរបស់កម្មករនិយោជិត ដូចនេះ និយោជកពុំគួរតម្រូវឱ្យកម្មករនិយោជិតបំពេញលក្ខខណ្ឌច្រើនយ៉ាងនេះទេ។
- នៅក្នុងសវនាការ ភាគីនិយោជកបានបញ្ជាក់បន្ថែមទៀតថា និយោជកនឹងសម្រួលនីតិវិធីនៃការជូនដំណឹងដូចខាងក្រោមនេះ:
    - បើមានការជូនដំណឹងពីកម្មករនិយោជិត និយោជកចាំបាច់ត្រូវតែផ្តល់ជូនតាមការស្នើនេះ។
    - កម្មករនិយោជិតត្រូវតែបំពេញលិខិតជូនដំណឹងនេះ តាមទំរង់ដែលមានស្រាប់ ហើយត្រូវជូនដំណឹងទៅប្រធានក្រុមជួរ ៦ ដោយមានហត្ថលេខាពីប្រធាន ក្រុម ឬជំនួយការប្រធាន ឡាញ (Line) ៦ នោះ។ បន្ទាប់មកត្រូវយកទៅបោះត្រានៅកន្លែងរដ្ឋបាល។
    - ប្រធានជួរ ៦ ត្រូវឱ្យមាននៅទីតាំងមួយច្បាស់លាស់ និងពិតប្រាកដ។
    - បើកម្មករនិយោជិតពុំចេះអក្សរទេ និយោជកនឹងចាត់ចែងឱ្យមានអ្នកជួយបំពេញលើទំរង់លិខិតនេះ។

**ហេតុផលនៃសេចក្តីសម្រេចៈ**

**ចំណុចវិវាទៈ កម្មករនិយោជិតទាមទារឱ្យនិយោជកអនុញ្ញាតឱ្យកម្មករនិយោជិតចេញទៅក្រៅរោងចក្រ នៅពេលឈប់សម្រាកបាយថ្ងៃត្រង់ ដោយមិនចាំបាច់មានលិខិតស្នាមឡើយ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាលើការទាមទារដូចខាងក្រោមនេះ:

តាមរយៈអង្គហេតុ និយោជកអនុញ្ញាតឱ្យកម្មករនិយោជិតឈប់សម្រាកពីការងារចំនួនមួយម៉ោង គឺពីម៉ោង ១១:០០ នាទី ដល់ម៉ោង ១២:០០ នាទី សម្រាប់បរិភោគបាយថ្ងៃត្រង់។ ចំពោះបាយថ្ងៃត្រង់មួយពេលនេះ និយោជកជាអ្នកផ្តល់ជូនដោយឥតគិតថ្លៃ។ ប៉ុន្តែបើក្នុងករណី កម្មករនិយោជិតចង់ទៅបរិភោគអាហារនៅខាងក្រៅបរិវេណរោងចក្រ ពួកគាត់ត្រូវជូនដំណឹងទៅនិយោជក ដោយបំពេញលើលិខិតសុំចេញ ហើយមានចុះហត្ថលេខារបស់ប្រធានក្រុមជួរ ៦ ទៀត។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ជាទូទៅម៉ោងសម្រាកបាយថ្ងៃត្រង់ របស់កម្មករនិយោជិតមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់និយោជកទេ ពោលគឺកម្មករនិយោជិតមានសិទ្ធិសម្រេចថា ខ្លួនចង់បរិភោគអាហារនៅខាងក្នុងបរិវេណរោងចក្រ ឬខាងក្រៅរោងចក្រ ដោយមិនចាំបាច់ជូនដំណឹងទៅក្រុមហ៊ុនទេ។

ប៉ុន្តែ នៅក្នុងករណីនេះ ដោយសារភាគីកម្មករនិយោជិត និងភាគីនិយោជកមានអនុសញ្ញារួមជាមួយគ្នា ទាក់ទងនឹងការផ្តល់អាហារថ្ងៃត្រង់មួយពេលដោយមិនគិតថ្លៃ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការតម្រូវឱ្យកម្មករនិយោជិតធ្វើការជូនដំណឹងទៅនិយោជក និងមានហត្ថលេខាពីប្រធានក្រុមជួរ ៦ គឺជាករណីសមហេតុផល និងស្របច្បាប់ ដែលនិយោជកអាចមានសិទ្ធិអនុវត្តបាន ព្រោះថា និយោជកត្រូវដឹងពីចំនួនកម្មករនិយោជិត ដែលពុំបរិភោគបាយនៅក្នុងក្រុមហ៊ុន ដើម្បីងាយស្រួលយកទៅទូទាត់ថ្លៃបាយជាមួយចុងភៅ។ ទាក់ទងទៅនឹងការតម្រូវឱ្យមានការចុះហត្ថលេខាពីប្រធានក្រុមជួរ ៦ នេះ គឺជាវិធីសាស្ត្ររបស់ក្រុមហ៊ុន ដើម្បីងាយស្រួលផ្ទៀងផ្ទាត់ និងការពារកុំឱ្យមានការបន្លំ ឬបោកប្រាស់ណាមួយកើតឡើងទៅលើក្រុមហ៊ុនប៉ុណ្ណោះ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតគួរតែសហការជាមួយនិយោជកក្នុងការជូនដំណឹងនេះ ដើម្បីជៀសវាងពីភាពមន្ទិលណាមួយ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលស្គាល់ថា ការបំពេញលើលិខិតសុំចេញនេះ ពិតជាមានការស្មុគស្មាញសម្រាប់កម្មករនិយោជិតប្រាកដមែន ដូចជាទាមទារត្រូវដាក់មូលហេតុ រីឯកម្មករខ្លះពុំចេះអក្សរ ហើយពេលខ្លះមានការលំបាកក្នុងការដើររកប្រធានក្រុមឱ្យមកចុះហត្ថលេខាលើលិខិតជូនដំណឹងចេញនេះទៀត។

នៅក្នុងសវនាការ ភាគីកម្មករនិយោជិតពុំចង់ឱ្យបញ្ជាក់មូលហេតុ ដែលចេញទៅក្រៅនេះទេ ព្រោះនេះគឺជាសិទ្ធិឯកជនរបស់កម្មករនិយោជិត ហើយវាពុំស្ថិតនៅក្នុងម៉ោងការងារ។

អនុសញ្ញារួម ប្រការ ២០ របស់ក្រុមហ៊ុនបានចែងថា "*... កម្មករនិយោជិតទាំងអស់ត្រូវបានអនុញ្ញាត ឱ្យចាកចេញពីបរិវេណរោងចក្រក្នុងម៉ោងសម្រាកត្រូវជូនដំណឹងដល់អ្នកត្រួតត្រា ដើម្បីរាប់ចំនួន និងដើម្បីសុវត្ថិភាពផងដែរ* "។

យោងតាមអនុសញ្ញារួមខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកតម្រូវឱ្យកម្មករនិយោជិតធ្វើការជូនដំណឹង ពោលគឺនិយោជកគ្រាន់តែចង់ដឹង ដើម្បីងាយស្រួលយកទៅទូទាត់ថ្លៃបាយ និងងាយស្រួលគ្រប់គ្រងប៉ុណ្ណោះ។ ដូចនេះ នៅក្នុងទំរង់លិខិតសុំចេញនេះ កម្មករនិយោជិតពុំចាំបាច់បញ្ជាក់ពីមូលហេតុទេ។

THE ARBITRATION COUNCIL

មួយវិញទៀត នៅក្នុងសវនាការ និយោជកបានជួយសម្រួលលើនីតិវិធីនៃការជូនដំណឹងនេះ ដូចជា :

- បើមានការជូនដំណឹងពីកម្មករនិយោជិត និយោជកចាំបាច់ត្រូវតែផ្តល់ជូនតាមការស្នើរនេះ។
- កម្មករនិយោជិត ត្រូវតែបំពេញលិខិតជូនដំណឹងនេះ តាមទំរង់ដែលមានស្រាប់ ហើយត្រូវជូនដំណឹងទៅប្រធានក្រុមជួរ ៦ ដោយមានហត្ថលេខា ពីប្រធានក្រុម ឬជំនួយការប្រធាន ឡាញ ៦ នោះ។ បន្ទាប់ត្រូវយកទៅបោះត្រានៅរដ្ឋបាល។
- ប្រធានជួរ ៦ ត្រូវឱ្យមាននៅទីតាំងមួយច្បាស់លាស់ និងពិតប្រាកដ។
- បើកម្មករនិយោជិត ពុំចេះអក្សរទេ និយោជកនឹងចាត់ចែងឱ្យមានអ្នកជួយបំពេញលើទំរង់លិខិតនេះ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធការទាមទាររបស់កម្មករនិយោជិត ដែលសុំជូនដំណឹងត្រឹមរដ្ឋបាល ដែលមានទីតាំងនៅច្រកចេញ នៅពេលកម្មករនិយោជិតចេញទៅបរិភោគអាហារថ្ងៃត្រង់នៅខាងក្រៅ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ :

## សម្រេច និង បង្គាប់

**ចំណុចវិវាទះ**

- បដិសេធការទាមទាររបស់កម្មករនិយោជិត ដែលសុំជូនដំណឹងត្រឹមរដ្ឋបាល ដែលមានទីតាំងនៅច្រកចេញ នៅពេលកម្មករនិយោជិតចេញទៅបរិភោគអាហារថ្ងៃត្រង់នៅខាងក្រៅ។
- ភាគីនិយោជកត្រូវសម្រួលនិតិវិធីសុំចេញទៅបរិភោគអាហារថ្ងៃត្រង់នៅខាងក្រៅ ដូចដែលបានលើកឡើងនៅក្នុងសវនាការចំនួន ៤ ចំណុច។ ប៉ុន្តែ នៅលើទំរង់នៃលិខិតសុំចេញ កម្មករនិយោជិតពុំចាំបាច់បញ្ជាក់ពីមូលហេតុទេ។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។*

## ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **ឈឹម តិរម្យ**

ហត្ថលេខា: ------------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **លឹម សុវណ្ណា**

ហត្ថលេខា: ------------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល ៖

ឈ្មោះ ៖ **អាំង អេងថុង**

ហត្ថលេខា: ------------------------------------